ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៤ អនក្រ.បក

# **អនុក្រឹត្យ**

## **ស្តីពីការសុំច្បាប់ឈប់ពិសេស**

## **នៃមន្ត្រីរាជការដែលឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ**

## **រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- តាមសំណើរបស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៨

# <u>សំរេច</u>

**<u>មាត្រា ១</u>** : អនុលោមតាមព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មន្ត្រីរាជការដែលមានចែងក្នុងមាត្រា ៣៥ នៃព្រះរាជក្រមនេះ ដែលគណៈបក្សរបស់ខ្លួនបានជ្រើសរើសជាបេក្ខជនតំណាងរាស្ត្រ មានសិទ្ធិទទួលការអនុញ្ញាតអោយឈប់ពិសេស ដោយរក្សាទុកបៀវត្ស អតីតភាពការងារ និងសោធននិវត្តន៍។ ការឈប់ពិសេសនេះ ត្រូវ បញ្ចប់នៅថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោត។

សាមីខ្លួនត្រូវដាក់ពាក្យសុំយ៉ាងតិចប្រាំពីរថ្ងៃ មុន ថ្ងៃចាប់ផ្តើមយុទ្ធនាការឃោសនា ជូនអាជ្ញាធរថ្នាក់លើតាមឋានានុក្រម ដែលជាអ្នកចេញច្បាប់អនុញ្ញាតអោយឈប់ ដោយមានសេចក្តីចម្លងមកទីស្តីការគណៈមន្ត្រី និងគណៈកម្មការធិការជាតិរៀបចំការបោះឆ្នោត។

**<u>មាត្រា ២</u>** : មន្ត្រីរាជការដែលជាប់ឆ្នោតជាអ្នកតំណាងរាស្ត្រ ត្រូវដាក់ក្នុងស្ថានភាពក្រៅក្របខ័ណ្ឌដើម ក្នុងអំឡុងអាណត្តិជាអ្នកតំណាងរាស្ត្រ។ មន្ត្រីនោះត្រូវធ្វើពាក្យមកក្រសួង ឬ ស្ថាប័នសាមីដែលគ្រប់គ្រងក្របខ័ណ្ឌរបស់ខ្លួន។

**<u>មាត្រា ៣</u>** : ចំពោះបេក្ខជនឈរឈ្មោះតំណាងរាស្ត្រ ដែលជាអនុរដ្ឋលេខាធិការ ត្រូវតែដាក់ពាក្យសុំច្បាប់ឈប់ពិសេសពីនាយករដ្ឋមន្ត្រី។ ដោយឡែកទីប្រឹក្សាជាមន្ត្រីរាជការ ការឈប់ពិសេសនេះត្រូវសុំទៅប្រធានស្ថាប័ន តាមករណីជាក់ស្តែងនីមួយៗ។

**<u>មាត្រា ៤</u>** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និងមន្ត្រីរាជការដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយបានល្អ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៨

| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
|---|---|
| **ហត្ថលេខានិងត្រា** | **ហត្ថលេខានិងត្រា** |
| **អ៊ុង ហួត** | **ហ៊ុន សែន** |

**<u>កន្លែងទទួល</u>**

-ខុទ្ទកាល័យព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី២
-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
-គ្រប់ក្រសួង ស្ថាប័ន
-ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជំរាបជូន
ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និង សម្តេចនាយករដ្ឋមន្ត្រីទី២
ដើម្បីសូមចុះហត្ថលេខា
**សហរដ្ឋមន្ត្រី**
ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ស្តីទី

| **ហត្ថលេខា** | **ហត្ថលេខា** |
|---|---|
| **សុខ អាន** | **ណារ៉ា តាន់** |